## ចលនាស្ត្រី គណបក្ស សម រង្ស៊ី

## សកម្មភាពចលនាស្ត្រីគណបក្ស សម រង្ស៊ី

កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ចលនាស្ត្រី គណបក្ស សម រង្ស៊ី បានរៀបចំមហាសន្និបាតចលនាស្ត្រីជាតិខ្មែរលើកទី៦ ដែលជាថ្ងៃបង្កើតចលនាស្ត្រីជាតិខ្មែរ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ លោកប្រធានគណបក្ស សម រង្ស៊ី ។




*ការបំភ្លឺភ្លើងទៀនតំណាងភាពយុត្តិធម៌ និងសច្ចធម៌ នៅក្នុងមហាសន្និបាតចលនាស្ត្រីគណបក្ស សម រង្ស៊ីលើកទី ៦*

សមាសភាពចូលរួមមាន សមាជិក-សមាជិកាគណបក្ស និងស្ត្រី ដែលជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ-សង្កាត់ ក្រុមប្រឹក្សារាជធានីខេត្ត-ក្រុង ស្រុក-ខណ្ឌ សមាជិកគណៈកម្មាធិការនាយក អ្នកតំណាងរាស្ត្រ ភ្ញៀវជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ៤00នាក់ (បួនរយ នាក់) ។

"ចលនាស្ត្រីជាតិខ្មែរ" ត្រូវបានប្តូរឈ្មោះមក **"ចលនាស្ត្រី គណបក្ស សម រង្ស៊ី"** វិញ ។




*វគ្គបណ្តុះបណ្តាលសមាជិកគណៈកម្មាធិការកណ្តាល*

លោកប្រធាន សម រង្ស៊ី បានមានប្រសាសន៍ថា គណបក្ស បានទទួលជោគជ័យ ដោយសារតែកម្លាំងស្ត្រី ព្រោះស្ត្រីជាដៃគូដ៏សំខាន់ជាមួយបុរស ដែលមិនអាចខ្វះបានក្នុងការចូលរួមចំណែកអភិវឌ្ឍន៏សង្គមជាតិ ។ ដូច្នេះយើងត្រូវតែផ្តល់តួនាទី និងបង្កើនសមត្ថភាពដល់ស្ត្រីអោយបានកាន់តែខ្លាំងក្លាជាងនេះថែមទៀត ។ មិនត្រឹមតែប៉ុណ្ណោះ លោកប្រធានបានប្រៀបប្រដូចស្ត្រីទៅ នឹង***ដង្កាប់ ឬញញួរ***រីឯបុរសវិញ លោកប្រៀបប្រដូចទៅនឹងថ្ម ដែល ***"ដង្កាប់ ឬ ញញួរអាចកែច្នៃថ្មបាន"*** ។



*កិច្ចប្រជុំសមាជិកគណៈកម្មាធិការកណ្តាលចលនាស្ត្រី*

ចលនាស្ត្រីគណបក្ស សម រង្ស៊ីបានបើកកិច្ចប្រជុំសមាជិកគណៈកម្មាធិការកណ្តាលចលនាស្ត្រី គណបក្ស សម រង្ស៊ី ក្រោមអធិបតីភាពរបស់លោកជំទាវ **មូរ សុខហួរ** ប្រធានចលនាស្ត្រីគណបក្សសម រង្ស៊ី កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ។ លទ្ធផលនៃកិច្ចប្រជុំនោះ បានជំរុញអោយចលនាស្ត្រីសំរេចទិសដៅ និងផែនការសកម្មភាពសំរាប់រយៈពេល ៣ឆ្នាំ របស់ខ្លួន ។

ក្រោយពីបានប្រជុំ សមាជិកគណៈកម្មាធិការកណ្តាលចលនាស្ត្រីគណបក្ស សម រង្ស៊ីរួចមក នៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០០៩ ចលនាស្ត្រីបានបើក

វគ្គបណ្ដុះបណ្ដាលសមាជិករបស់ខ្លួនស្ដីពី " ***ការពង្រឹងសមត្ថភាពស្ត្រី និងភាពជាអ្នកដឹកនាំ*** " ។ ក្នុងវគ្គ



*ការពិភាក្សាក្រុមដើម្បីស្វែងរកចំណុចខ្លាំង និងចំណុចខ្វះខាត*

បណ្ដុះបណ្ដាលនោះ ស្ត្រីជាអ្នកដឹកនាំបានខិតខំរិះរកចំណុចសំខាន់ៗសំរាប់រយៈពេល ៣ឆ្នាំក្នុងអាណត្តិទី៦ ដែលរួមមានទាំងចំណុចខ្លាំង និងចំណុចខ្វះខាតក្នុងការកំណត់យុទ្ធសាស្ត្រ និងរៀបចំរចនាសម្ព័ន្ធ ដែលបានបាត់បង់ឡើងវិញ ។

-ឆ្នាំ២០០៧ ស្ត្រីជាប់ជាក្រុមប្រឹក្សាឃុំ/សង្កាត់មាន ចំនួន ២៤៩រូប និងមេឃុំ/ចៅសង្កាត់មានចំនួន ៤រូប
-ឆ្នាំ២០០៨ ស្ត្រីជាប់ជាអ្នកតំណាងរាស្ត្រចំនួន ៦រូប
-ឆ្នាំ២០០៩ ស្ត្រីជាប់ជាក្រុមប្រឹក្សារាជធានីខេត្ត/ក្រុងស្រុក/ខណ្ឌមានចំនួន ៤២រូប រាជធានី/ខេត្តចំនួន ៣រូប ។

ដើម្បីអោយចំនួនស្ត្រីនៃគណបក្ស សម រង្ស៊ី កើនឡើងនៅឆ្នាំ ២០១២-២០១៣ ចលនាស្ត្រីគណបក្ស សម រង្ស៊ី មានផែនការសកម្មភាពរៀបចំរចនាសម្ព័ន្ធរាជធានី-ខេត្ត/ក្រុងទូទាំងប្រទេស ប្រមូលផ្ដុំស្ត្រីគ្រប់ស្រទាប់វណ្ណៈ ជាពិសេសកម្មករ-កម្មការិនី កសិករ អាជីវករ និងមន្ត្រីរាជការ តាមរយៈការបើកវគ្គបណ្ដុះបណ្ដាល ។

លោកជំទាវ **មូរ សុខហួរ** អ្នកតំណាងរាស្ត្រមណ្ឌលកំពត ប្រធានក្រុមប្រឹក្សាគណបក្ស សម រង្ស៊ី ខេត្តកំពត និងជាប្រធានចលនាស្ត្រីគណបក្ស សម រង្ស៊ី ត្រូវបានតុលាការកាត់សេចក្ដីអោយចាញ់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន យ៉ាងអយុត្តិធម៌ ហើយតំរូវអោយលោកជំទាវ បង់ប្រាក់ចំនួន ១៦,៥០០,០០០រៀល (ដប់ប្រាំមួយលានប្រាំសែនរៀលគត់) ។



*លោកជំទាវ មូរ សុខហួរ នៅពីមុខតុលាការដំបូងរាជធានីភ្នំពេញ*



*ក្បួនដង្ហែររកភាពយុត្តិធម៌*

បន្ទាប់មកលោកជំទាវ មូរ សុខហួរ បានស្រែកតវ៉ានូវចំពោះមុខតុលាការថា (ការកាត់ក្ដីរបស់តុលាការរាជធានីភ្នំពេញនេះ គ្មានយុត្តិធម៌ទាល់តែសោះមកលើរូបលោកជំទាវក៏ដូចជាប្រជាពលរដ្ឋខ្មែរទូទៅ) ការកាត់ក្ដីនេះគឺជាការកាត់ក្ដីក្រោមការត្រួតត្រារបស់ អ្នកកាន់អំណាចនៅប្រទេសកម្ពុជា ។ លោកជំទាវ និងក្រុមស្ត្រីបានអុជទៀន ដង្ហែរក្បួនជាមួយលោកប្រធាន សម រង្ស៊ី អ្នកតំណាងរាស្ត្រ និងសកម្មជនគណបក្ស ព្រមទាំងអ្នកកាសែតជាតិ និងអន្តរជាតិមួយចំនួន ឆ្ពោះទៅកាន់ទីស្នាក់ការគណបក្ស ប៉ុន្តែត្រូវបានកងកម្លាំងប្រដាប់អាវុធ វាយបំបែកមកលើក្បួនដង្ហែរនេះយ៉ាងសាហាវ

*ចលនាស្ត្រីគណបក្ស សម រង្ស៊ី បានចាក់ផ្សាយពីសកម្មភាពរបស់ខ្លួន និងសម្លេងស្ត្រីតាមវិទ្យុពន្លឺភ្លើងទៀន FM ៩៣.៥ MHz ជារៀងរាល់ថ្ងៃសៅរ៍ នៅវេលាម៉ោង ៦ : ០០ល្ងាច ដល់ម៉ោង ៧ : ០០យប់ ។*